# ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ២០១៩-២០២៣

*សេចក្តីសង្ខេបនៃការពិភាក្សាពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល*

ភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

<u>អ្នកចូលរួម៖</u> តំណាងចំនួន ៤១នាក់ មកពីអង្គការសង្គមស៊ីវិល ក្នុងនោះមានអង្គការមិនមែនរដ្ឋាភិបាលនៅតាមខេត្ត ផងដែរ។

<u>សេចក្តីផ្តើម៖</u> ធនាគារពិភពលោកបើកកិច្ចពិគ្រោះយោបល់នេះដោយធ្វើបទបង្ហាញសង្ខេបពីអំពីបរិបទរបស់ប្រទេស និងអាទិភាពនានាក្នុងកិច្ចការអភិវឌ្ឍន៍ ដូចត្រូវបានរកឃើញតាមរយៈការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធ (SCD) ព្រមទាំងសំណើវិស័យត្រូវផ្តោតយកចិត្តទុកដាក់សម្រាប់ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) ដែលស្របតាមអាទិភាពរបស់យុទ្ធសាស្រ្តចតុកោណនៃរាជរដ្ឋាភិបាលកម្ពុជា។ បណ្តាវិស័យត្រូវផ្តោតយកចិត្តទុកដាក់ក្នុងក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា (CPF) រួមមាន៖ ១) លើកកម្ពស់ប្រសិទ្ធផលរបស់រដ្ឋ និងជំរុញការអភិវឌ្ឍវិស័យឯកជន, ២) ជំរុញការអភិវឌ្ឍមនុស្ស, ៣) កែលម្អវិស័យកសិកម្ម និងពង្រឹងការប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិឱ្យកាន់តែប្រសើរ និងមូលបទអន្តរវិស័យស្តីពីការពង្រឹងអភិបាលកិច្ច ស្ថាប័ន និងការចូលពាក់ព័ន្ធរបស់ពលរដ្ឋ។ បន្ថែមលើមាគ៌ាដែលត្រូវបានគ្រួសត្រាយដោយការវិនិច្ឆ័យស្ថានភាពប្រទេសមានលក្ខណៈជាប្រព័ន្ធ (SCD) និងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ក្របខណ្ឌភាពជាដៃគូសម្រាប់ប្រទេសកម្ពុជា មានគោលដៅពិចារណាមើលអំពីឧត្តមភាពប្រៀបធៀបនៃវិស័យគម្រោងអនុវត្តនានារបស់ក្រុមធនាគារពិភពលោក។ នៅក្នុងកិច្ចពិគ្រោះយោបល់នេះ អ្នកចូលរួមត្រូវបានបែងចែកជាក្រុមៗឱ្យធ្វើការជជែកបំផុសគំនិត កត់ត្រាចម្លើយតបទៅនឹងសំណួរពិភាក្សារបស់ធនាគារពិភពលោក ហើយបន្ទាប់មកធ្វើបទបង្ហាញអំពីការសន្និដ្ឋានតាមក្រុមរៀងៗខ្លួន។

<u>បញ្ហាធំៗដែលត្រូវបានលើកឡើងនៅក្នុងកិច្ចពិភាក្សា៖</u> មូលធនមនុស្ស កិច្ចគាំពារសង្គម គណនេយ្យភាពសង្គម បរិស្ថាន និងសហគ្រាសខ្នាតតូចនិងមធ្យម។

| វិស័យដែលត្រូវបានលើកយកមកពិភាក្សា | ចំណុចគោលសំខាន់ៗដែលបានលើកឡើង |
|---|---|
| **តើអ្វីខ្លះទៅជាបញ្ហាប្រឈម និងភាពចាំបាច់បន្ទាន់ជាងគេនៅក្នុងការអភិវឌ្ឍរបស់** | • ការអភិវឌ្ឍមនុស្ស និងការអប់រំ៖ សិស្សជាច្រើននៅមិនទាន់បានត្រៀមខ្លួនគ្រប់គ្រាន់សម្រាប់ការអប់រំកម្រិតឧត្តមសិក្សា។ នៅតាមតំបន់ខ្លះ អត្រាសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានត្រឹមតែ ៦០ភាគរយប៉ុណ្ណោះ។ គុណភាពនៃការអប់រំនៅមិនទាន់មានលក្ខណៈស្មើគ្នា ធ្វើឱ្យយុវជនជាច្រើននៅមានកម្រិតជំនាញទាប មិនអាចត្រៀមខ្លួនបានសមស្របតាម |

| | |
|---|---|
| ប្រទេសកម្ពុជា ? | តម្រូវការទីផ្សារ ដែលធ្វើឱ្យពួកគេនៅវិលវល់ជាប់ក្នុងវដ្តនៃភាពក្រីក្រឥតឈប់ឈរ។<br>• សិទិទ្ធពល(ភាពស្ថិតរម្មេត)ផ្នែកសង្គម អំពើពុករលួយ និងកម្រិតទាបនៃការទុកចិត្តរបស់មហាជនចំពោះស្ថាប័នសាធារណៈ នៅតែជាបញ្ហាសំខាន់នៅឡើយ។ រវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលមានការទុកចិត្តគ្នាតិចណាស់ ដែលចាំបាច់ត្រូវខិតខំអភិវឌ្ឍកែលម្អឱ្យប្រសើរឡើង។<br>• អភិបាលកិច្ចដីធ្លីនៅតែបន្តមានបញ្ហានៅកម្ពុជា ហើយ ជាពិសេស បង្កផលប៉ះពាល់ច្រើនដល់ជនជាតិដើមភាគតិច។ ភាពចាំបាច់ត្រូវមានការគ្រប់គ្រងដីសម្បទានឱ្យបានល្អប្រសើរជាងបច្ចុប្បន្ន ដើម្បីបញ្ចៀសបញ្ហានៃភាពត្រួតស៊ីគ្នានៃព្រំដីរវាងសហគមន៍ និងក្រុមហ៊ុនឯកជន។ នៅពេលណាមានជម្លោះកើតឡើង យន្តការដោះស្រាយបញ្ហាដំណើរការមិនបានល្អ។ ដំណើរការធ្វើប័ណ្ណកម្មសិទ្ធិដីសមូហភាពនៅមានភាពយឺតយ៉ាវ និងនៅតែស្មុគស្មាញ។<br>• ការធ្វើចំណាកស្រុកគឺជាបញ្ហាប្រឈមបន្ទាន់មួយ។ ការធ្វើចំណាកស្រុកនេះមានផលប៉ះពាល់ដល់កម្លាំងពលកម្មនិងជំនាញ កិច្ចគាំពារសង្គម និងសេដ្ឋកិច្ចជាតិ។ ប្រទេសកម្ពុជាត្រូវការយន្តការមួយដើម្បីគ្រប់គ្រងមូលធនមនុស្សរបស់ខ្លួន និងរិះរកមធ្យោបាយដើម្បីប្រើប្រាស់ការធ្វើចំណាកស្រុកនៃសម្រាប់កែលម្អសេដ្ឋកិច្ចជាតិឱ្យបានកាន់តែប្រសើរឡើង។ ចាំបាច់ត្រូវជំរុញលើកទឹកចិត្តឱ្យមានការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ ការធ្វើចំណាកស្រុកក្នុងប្រទេសក៏នាំឱ្យមានបញ្ហាពាក់ព័ន្ធនឹងការរៀបចំនគរូបនីយកម្មផងដែរ។<br>• ទាក់ទិនទៅនឹងការធ្វើចំណាកស្រុកនេះដែរ គឺទម្លាប់អនុវត្តន៍នៃការឱ្យខ្ចីប្រាក់ខ្វះការទទួលខុសត្រូវរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន។ ទម្លាប់អនុវត្តន៍បែបនោះចាំបាច់ត្រូវដាក់ក្រោមការធ្វើនិយតកម្មឱ្យបានល្អប្រសើរជាងបច្ចុប្បន្ន ដោយសារថាកន្លងមកមានមនុស្សមួយចំនួនជំពាក់បំណុលគេច្រើន ហើយជ្រើសរើសយកការធ្វើចំណាកស្រុកជាមធ្យោបាយតែមួយគត់របស់ពួកគាត់សម្រាប់សងបំណុលគេវិញ។<br>• ការគាំពារសង្គមមានការអភិវឌ្ឍទៅមុខខ្លះៗ ប៉ុន្តែនៅតែមានភាពខ្វះខាតច្រើននៅឡើយប្រៀបទៅនឹងសេចក្តីត្រូវការ។ ចំណុចនេះក៏មានទំនាក់ទំនងផងដែរទៅនឹងការកែលម្អទូទៅដែលចាំបាច់ត្រូវមាននៅក្នុងការផ្តល់សេវាសាធារណៈ។ ភាពគ្រប់ដណ្តប់ជាសាកលនៃការធានារ៉ាប់រងផ្នែកសុខភាព គឺជាផ្នែកមួយគួរឱ្យចាប់អារម្មណ៍នៅក្នុងកិច្ចគាំពារសង្គម។<br>• ថ្វីបើសេដ្ឋកិច្ចទទួលបានកំណើនរឹងមាំក៏ពិតមែន កំណើននេះមិនត្រូវបានយកទៅបែងចែកឱ្យបានស្មើភាពនៅក្នុងចំណោមប្រជាជនទេ។ ក្រុមជនងាយរងគ្រោះ និងក្រុមពលរដ្ឋដែលត្រូវគេផាត់ចេញពីការយកចិត្តទុកដាក់ គ្មានឱកាសទទួលបានអត្ថប្រយោជន៍ពីកំណើននោះទេ។ |

| | |
|---|---|
| | • នៅមានពលរដ្ឋច្រើនដែលគ្មានលទ្ធភាពរកបានសេវា ឬព័ត៌មានរបស់ប្រព័ន្ធយុត្តិធម៌។<br>• ប្រទេសកម្ពុជាបានរៀបចំបង្កើតបានគោលនយោបាយល្អមួយចំនួន ប៉ុន្តែគម្លាតនៅតែមានរវាងគោលនយោបាយ និងការអនុវត្ត។ ការអនុវត្តច្បាប់មិនបានល្អនៅតែបន្តមាន ជាពិសេសនៅតាមថ្នាក់ក្រោមៗរបស់រាជរដ្ឋាភិបាល។<br>• ការប្រើប្រាស់គ្រឿងញៀន ជាពិសេសក្នុងចំណោមយុវវ័យ គឺជាបញ្ហាមួយដែលអាចធ្វើឱ្យប្រទេសខ្សោះមូលធនមនុស្សរបស់ខ្លួន។<br>• វិស័យកសិកម្មនៅតែបន្តធ្លាក់នៅពីក្រោយប្រទេសដទៃទៀត ហើយចាំបាច់ត្រូវមានការអភិវឌ្ឍ និងការធ្វើពាណិជ្ជកម្មឱ្យបានខ្លាំងក្លាបន្ថែមទៀត។ ការប្រែប្រួលអាកាសធាតុបានបង្កផលប៉ះពាល់អវិជ្ជមានលើវិស័យកសិកម្ម ហើយកសិករជនបទត្រូវការប្រព័ន្ធធារាសាស្ត្រផ្គត់ផ្គង់ទឹកធ្វើកសិកម្ម។<br>• សហគ្រាសខ្នាតតូចនិងមធ្យមចាំបាច់ត្រូវធ្វើការអភិវឌ្ឍខ្លាំងថែមទៀត ហើយដំណើរការនីតិវិធីសម្រាប់ការបើកធ្វើធុរកិច្ចក៏ត្រូវតែធ្វើឱ្យមានភាពងាយស្រួលជាងបច្ចុប្បន្នដែរ។<br>• មណ្ឌលសុខភាពជាច្រើននៅមានគុណភាពមិនស្មើគ្នា ដោយក្នុងនោះមានជំនាញ និងគ្រឿងបរិក្ខារកម្រិតខុសៗគ្នា។ |
| **តើមានអ្វីខ្លះជាវិស័យអាទិភាពសម្រាប់ក្រុមធនាគារពិភពលោកបន្តជួយឧបត្ថម្ភនៅក្នុងអំឡុងពេល៥ឆ្នាំខាងមុខ? មានអ្វីខ្លះដែលក្រុមធនាគារពិភពលោកគួរបន្តសកម្មភាពជួយបន្ថែមទៀត ឬបន្ថយ សកម្មភាពវិញ?** | • ជារួម ធនាគារពិភពលោកគួរធ្វើការវិនិយោគតិចជាងមុនលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហើយងាកទៅផ្តោតលើអាទិភាពផ្សេងៗវិញ នៅពេលដែលប្រទេសកម្ពុជាអាចរកហិរញ្ញវត្ថុសម្រាប់ហេដ្ឋារចនាសម្ព័ន្ធពីអ្នកឱ្យខ្ចីប្រាក់ផ្សេងទៀតបាន។<br><br>*ការអភិវឌ្ឍមនុស្ស*<br>• ការគាំពារសង្គមត្រូវបានអ្នកចូលរួមពិគ្រោះយោបល់ជាច្រើនលើកឡើងថាជាអាទិភាពសម្រាប់ឱ្យមានការគាំទ្រពីសំណាក់ធនាគារពិភពលោក។ តាមដែលអាចធ្វើទៅបាន ប្រព័ន្ធគាំពារសង្គមគួរតែត្រូវបានផ្សារភ្ជាប់គ្នា ដើម្បីជានាឱ្យមានការឆ្លើយតបទាន់ពេលវេលាទៅនឹងវិបត្តិ និងដើម្បីចៀសវាងការធ្វើការងារនៅដាច់ដោយឡែកៗពីគ្នា។<br>• ធនាគារពិភពលោកគួរពិចារណាចូលពាក់ព័ន្ធក្នុងផ្នែកអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ មិនគួរពាក់ព័ន្ធតែក្នុងផ្នែកឧត្តមសិក្សាទេ។<br>• អ្នកចូលរួមបានសួរថាតើមានឱកាសដែលធនាគារពិភពលោកអាចចូលរួមក្នុងបញ្ហាគ្រប់គ្រងលើការធ្វើចំណាកស្រុកដែរឬទេ ពីព្រោះវានេះគឺជាបញ្ហាប្រឈមដែលកំពុងបន្តមាន ហើយដែលបណ្តាលឱ្យមានការខ្វះខាតកម្លាំងពលកម្ម និងជំនាញនៅក្នុងប្រទេស សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ |

- ធនាគារពិភពលោកគួរតែធ្វើការដើម្បីធានាឱ្យមានការបែកចែក ដោយយុត្តិធម៌ផលកំណើនសេដ្ឋកិច្ចឱ្យបានទៅដល់ក្រុមប្រជាជនងាយរងគ្រោះបំផុត ដោយគិតគូរក្រុមពលរដ្ឋច្រើនប្រភេទ មានដូចជា ជនពិការ, ក្រុមអ្នកស្រលាញ់ភេទដូចគ្នា, កុមារ, ស្ត្រី, និងជនជាតិដើមភាគតិច។ ការគិតគូរនេះនេះគួរតែមាននៅក្នុងអំឡុងពេលអនុវត្តគម្រោងរបស់ធនាគារពិភពលោក។ តើក្រុមមនុស្សទាំងនេះដែលទទួលបានការគិតគូរដល់ទេកន្លងមក?
- ការចូលពាក់ព័ន្ធរបស់ធនាគារពិភពលោកក្នុងការអភិវឌ្ឍមូលធនមនុស្សទទួលបានការឱ្យតម្លៃកោតសរសើរ ហើយដូច្នេះវាគួរតែបន្តនៅជាផ្នែកមួយសម្រាប់ការវិនិយោគនៅគ្រប់កម្រិតទាំងអស់ រាប់ទាំងការអភិវឌ្ឍកុមារតូច និងយុវជនផងដែរ។
- គួរមានការចូលពាក់ព័ន្ធនៅក្នុងការធ្វើឱ្យប្រសើរដល់សន្តិសុខស្បៀង និងលទ្ធផលអាហារូបត្ថម្ភ។
- គម្រោងរបស់ធនាគារពិភពលោកពាក់ព័ន្ធផ្នែកសុខាភិបាលគួរផ្តោតទាំងទៅលើសមធម៌ និងគុនភាពរបស់សេវាថែទាំសុខភាព។

*អភិបាលកិច្ច និងសេដ្ឋកិច្ច*

- គណនេយ្យភាពសង្គម៖ ការជួយគាំទ្ររបស់ធនាគារពិភពលោកគួរតែមានការគិតគូរដល់កំណែទម្រង់វិស័យសាធារណៈនៅគ្រប់កម្រិត និងគោលនយោបាយផង ដើម្បីកាត់បន្ថយអំពើពុករលួយនិងលើកកម្ពស់យុត្តិធម៌សង្គម។
- ធនាគារពិភពលោកគួរជួយគាំទ្រធ្វើឱ្យមានប្រព័ន្ធយុត្តិធម៌កាន់តែមានភាពទុកចិត្តបានជាងមុន តាមមធ្យោបាយណាក៏ដោយដែលអាចធ្វើទៅរួច។
- អ្នកចូលរួមក្នុងការពិគ្រោះយោបល់បានគាំទ្រដល់ការជ្រើសរើសយកវិស័យផ្តោតការយកចិត្តទុកដាក់ទី១ របស់ធនាគារពិភពលោក ហើយគេបានស្នើទៀតដែរឱ្យមានថវិកាបន្ថែមទៀត ដើម្បីគាំទ្រដល់ការងារអភិបាលកិច្ចល្អ និងគណនេយ្យភាពសង្គម។ ក្នុងនេះអាចរួមបញ្ចូលទាំងការកែលម្អសមត្ថភាពនៃវិស័យសាធារណៈ និងការគាំទ្រដល់កំណែទម្រង់ស៊ីវិល។
- ធនាគារពិភពលោកគួរតែធ្វើការលើការពង្រឹងសមត្ថភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការផ្តល់កម្មសិទ្ធិដីសហគមន៍។ គម្រោងបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច (LASED) គួរតែបន្តធ្វើទៅទៀត។
- ការអភិវឌ្ឍសមត្ថភាពគឺជាការចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យប្រសើរនូវប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មសាធារណៈ។

*វិស័យឯកជន*

- ធនាគារពិភពលោកគួរធ្វើការលើការរៀបចំបទប្បញ្ញត្តិនិងការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម។ ក្នុងនេះអាចរួមមានការធ្វើឱ្យក្របខណ្ឌច្បាប់កាន់តែមានភាពប្រសើរឡើង និងធ្វើឱ្យការចុះឈ្មោះបើកធុរកិច្ចកាន់តែមានភាពងាយស្រួល។
- ផលិតផលក្នុងស្រុកចាំបាច់មានការការគាំទ្រដើម្បីអាចទទួលបានតម្លៃសមរម្យ និងអាចប្រកួតប្រជែងជាមួយគម្រោងដែលនាំចូល ក៏ដូចជានៅក្នុងទីផ្សារក្នុងតំបន់ដែរ។
- ក្នុងការចូលពាក់ព័ន្ធរបស់ខ្លួនជាមួយវិស័យឯកជន ការលើកកម្ពស់ទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនគួរតែជាអាទិភាពសម្រាប់ធនាគារពិភពលោក។
- វិស័យបច្ចេកវិជ្ជាមានសក្តានុពលសម្រាប់ប្រទេសកម្ពុជា ហើយក៏អាចជាផ្នែកថ្មីមួយសម្រាប់ធនាគារពិភពលោកពិនិត្យមើលលទ្ធភាពចូលរួមពាក់ព័ន្ធផងដែរ។
- មូលនិធិវិនិយោគលើផលប៉ះពាល់ខាងសង្គមកិច្ចគឺជាជម្រើសល្អមួយដើម្បីធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមាននៅក្នុងវិសមភាពសង្គម។
- មនុស្សជាច្រើននៅតែជួបការលំបាកក្នុងការរកទទួលបានហិរញ្ញវត្ថុ ជាពិសេសកសិករនៅតាមជនបទ។ ចំណុចនេះគួរតែត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងដែលមានស្រាប់។

*បរិស្ថាន និងកសិកម្ម*

- ធនាគារពិភពលោកគួរចាត់ទុកកំណើនបៃតង និងនិរន្តរភាពបរិស្ថានជាវិស័យអាទិភាពមួយ។ នៅទូទាំងសកលលោក ការវិនិយោគអភិវឌ្ឍន៍ចាំបាច់ត្រូវតម្រង់ទិសឆ្ពោះទៅរកភាពធន់ទ្រាំនឹងអាកាសធាតុ។ រាជរដ្ឋាភិបាលកម្ពុជាមានយុទ្ធសាស្ត្រកំណើនបៃតងដែលធនាគារពិភពលោកអាចចូលរួមគាំទ្រ។
- សូមធ្វើការវាយតម្លៃកោតសរសើរដល់ការគាំទ្ររបស់ធនាគារពិភពលោកនាពេលខាងមុខចំពោះវិស័យកសិកម្ម។ នៅក្នុងការចូលពាក់ព័ន្ធរបស់ធនាគារពិភពលោកក្នុងវិស័យកសិកម្ម អ្នកចូលរួមពិគ្រោះយោបល់បានស្នើឱ្យមានការគាំទ្រដល់ការបង្កើតប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធកសិកម្មដែលពាក់ព័ន្ធ។
- គម្រោងរបស់ធនាគារពិភពលោកគួរតែលើកកម្ពស់ការធ្វើឱ្យផលិតកម្ម និងការធ្វើពាណិជ្ជកម្មផលិតផលកសិកម្មកាន់តែមានភាពប្រសើរឡើង ដែលរួមបញ្ចូលទាំងលទ្ធភាពរកកទទួលបានហិរញ្ញវត្ថុ និងការផ្សារភ្ជាប់ជាមួយទីផ្សារផង។

| | |
|---|---|
| | • អ្នកចូលរួមក្នុងការពិគ្រោះយោបល់បានយល់ស្របជាមួយការចូលពាក់ព័ន្ធរបស់ធនាគារពិភពលោកក្នុងការងារស្តីពីការគ្រប់គ្រងចម្រុះលើធនធានទឹកទន្លេមេគង្គ ហើយពួកគេសង្កត់ធ្ងន់ថាការពាក់ព័ន្ធគួរតែបន្តទៅមុខទៀត។<br>• គួរតែមានគម្រោងគាំទ្រដល់វិស័យទេសចរណ៍ និងអេកូទេសចរណ៍ ជាពិសេស។ កាគាំទ្របែបនេះអាចផ្តល់ការលើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការអភិរក្សធម្មជាតិ។<br>• ធនាគារពិភពលោកគួរវិនិយោគលើថាមពលកកើតឡើងវិញ ដែលជាមធ្យោបាយមួយសម្រាប់ផ្គត់ផ្គង់ថាមពលមានតម្លៃទាបនៅតំបន់ជនបទ។ |
| *តើមានអ្វីខ្លះដែលអាចជាបញ្ហាប្រឈមគួរឱ្យកត់សម្គាល់សម្រាប់ការអនុវត្ត ហើយថាតើបញ្ហាប្រឈមទាំងនោះអាចត្រូវបានកាត់បន្ថយតាមរបៀបណាខ្លះ ?* | • អំពើពុករលួយនៅតែជាបញ្ហាប្រឈមឆ្លងកាត់គ្រប់ផ្នែកទាំងអស់។ បញ្ហានេះអាចត្រូវបានកាត់បន្ថយសម្រាលមកវិញបានខ្លះតាមរយៈការគាំទ្រដល់ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យប្រសើរឡើង និងតាមរយៈការគាំទ្រស្ថាប័នរដ្ឋាភិបាលឱ្យមានការអនុវត្តផ្តល់សេវាកាន់តែមានប្រសិទ្ធភាពជាងមុន។ ប្រព័ន្ធព័ត៌មានវិទ្យាក៏ត្រូវបានលើកឡើងដែរថាមានសក្តានុពលដើម្បីធ្វើឱ្យប្រតិបត្តិការនានាកាន់តែមានតម្លាភាពថែមទៀតនាពេលអនាគត។ ការកសាងតម្លាភាពគឺជាដំណើរការមានល្បឿនយឺតមែន ប៉ុន្តែវាអាចធ្វើទៅបានតាមរយៈការកំណត់ស្តង់ដា និងដំណើរការច្បាស់លាស់។<br>• អ្នកចូលរួមក្នុងការពិគ្រោះយោបល់បានលើកឡើងអំពីបញ្ហាប្រឈមនយោបាយ ទាំងក្នុងនិងក្រៅប្រទេស ដែលមានផលប៉ះពាល់ដល់គម្រោងនានា។<br>• អង្គការសង្គមស៊ីវិលបានលើកឡើងពីការព្រួយបារម្ភថាតើការវិនិយោគលើគម្រោងតែងតែឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមដែលពាក់ព័ន្ធដែរឬទេ ហើយពួកគេបានលើកទឹកចិត្តដល់ធនាគារពិភពលោកថា នៅក្នុងពេលត្រួតពិនិត្យគម្រោងដែលកំពុងអនុវត្ត គួរធានាយ៉ាងណាឱ្យការបញ្ចេញសំឡេងរបស់ប្រជាពលរដ្ឋក្នុងតំបន់គម្រោងត្រូវបានលើកកម្ពស់ និងឱ្យតម្លៃ។ អ្នកចូលរួមកិច្ចពិគ្រោះយោបល់បានសួរថាតើអាចមានយន្តការណាមួយសម្រាប់ការចូលរួមជាសាធារណៈ លើសពីដំណាក់កាលពិគ្រោះយោបល់ដែរឬទេ ?<br>• ធនធានមនុស្ស និងធនធានបច្ចេកទេសនៅតែមានកម្រិតនៅឡើយ សម្រាប់ការអនុវត្តគម្រោង ជាពិសេសនៅថ្នាក់ក្រោមជាតិ។ |
| *អត្ថាធិប្បាយផ្សេងៗទៀត* | • អ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់បានយល់ស្របថា វាជាប្រការមួយមានប្រយោជន៍ប្រសិនបើមានការចែករំលែកព័ត៌មានឱ្យបានល្អប្រសើរជាងមុនពីសំណាក់ធនាគារពិភពលោក។ ពួកគេចង់ឃើញមានភាពច្បាស់លាស់បន្ថែមទៀតអំពីឱកាស និងចំណុចច្រកចូលសម្រាប់ធ្វើការសម្របសម្រួលរវាងអង្គការសង្គមស៊ីវិល និងធនាគារពិភពលោក ( និងដៃគូអភិវឌ្ឍន៍ផ្សេង |

| | |
|---|---|
| | ទៀត) ។<br>• អង្គការសង្គមស៊ីវិលសូមស្វាគមន៍ចំពោះលទ្ធភាពមានការពិភាក្សាបន្ថែមទៀតជាមួយធនាគារពិភពលោក ស្តីពីរបៀបធ្វើការពាក់ព័ន្ធជាមួយប្រជាពលរដ្ឋតាមរយៈគម្រោង និងអំពីថាតើធ្វើដូចម្តេចដើម្បីឱ្យមានបណ្តាញប្រាស្រ័យទាក់ទងគ្នាកាន់តែមានភាពប្រសើរជាងមុន។<br>• អ្នកចូលរួមមួយចំនួននៅក្នុងកិច្ចពិគ្រោះយោបល់នេះបានស្នើឱ្យមានការសម្របឱ្យបានកាន់តែល្អជាងមុនជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងក្នុងការសហការជាមួយសហគមន៍ ជាមួយដៃគូអភិវឌ្ឍន៍ រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីធ្វើឱ្យមានការយល់ដឹងកាន់តែប្រសើរអំពី SDGs និងអំពីការថាតើគេអាចយក SDGs ទៅអនុវត្តទៅក្នុងកម្មវិធីនានាបានដោយរបៀបណាខ្លះ ហើយវឌ្ឍនភាពរបស់វាអាចត្រូវបានវាស់វែងបានដោយវិធីណាដែរ។<br>• អ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់ក៏បានស្នើផងដែរឱ្យធនាគារពិភពលោកជួយពិនិត្យមើលបញ្ហាបំណុល (បំណុលដែលប្រជាជនខ្ចីពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ។ |